# វគ្គបណ្ដុះបណ្ដាល ស្ដីពីៈ

# មូលហេតុ និងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ

## ការអនុវត្តកសិកម្មវៃឆ្លាតនឹងអាកាសធាតុ

Climate Smart of Agriculture





រៀបចំដោយៈ ក្រុមការខាគម្រោងខ្សែច្រវាក់ផលិតកម្មដោយតាគរៈបរិស្ថាន

# មាតិកា



១. សេចក្តីផ្តើម



២. សរសរស្តម្ភនៃកសិកម្មវៃឆ្លាតធន់នឹងអាកាសធាតុ



៣. ការអនុវត្តបច្ចេកទេសសំខាន់ៗធន់នឹងអាកាសធាតុក្នុងផលិតកម្មកសិកម្ម

# ទីតាំងអនុវត្តគម្រោង និងប្រភេទមុខដំណាំ




## ទីតាំងអនុវត្តគម្រោង៖

1. ខេត្តតាកែវ
2. ខេត្តកំពត
3. ខេត្តកំពង់ចាម
4. ខេត្តត្បូងឃ្មុំ

## ប្រភេទមុខដំណាំ៖

1. ដំណាំស្រូវ
2. ពោត
3. ដំឡូងមី
4. ដំណាំស្វាយ

# ព័ត៌មានសង្ខេបនៃគម្រោង

- គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន បាន និងកំពុងអនុវត្ត៖
  ១. ជួយគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់រដ្ឋាភិបាល ដែលមានបំណងធ្វើឲ្យប្រសើរឡើងនូវការប្រកួតប្រជែងនៃខ្សែច្រវាក់ផលិតកម្មនៅខេត្តកំពង់ចាម ត្បូងឃ្មុំ កំពត និងខេត្តតាកែវ។
  ២. ជម្រុញភាពធន់ទ្រាំនឹងអាកាសធាតុ នៃហេដ្ឋារចនាសម្ព័ន្ធកសិកម្មសំខាន់ៗ និងជួយក្នុងការធ្វើពាណិជ្ជកម្មលើផលិតកម្មដំណាំស្រូវ ពោត ដំឡូងមី និងស្វាយ។
  ៣. ជួយបង្កើនផលិតភាព និងពិពិធកម្មដំណាំ ការកែលម្អសមត្ថភាពឃ្លាំងស្តុក, ការកែច្នៃ និងការធ្វើតេស្តគុណភាព និងសុវត្ថិភាពផលិតផល ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ថាមពលព្រះអាទិត្យ និង ថាមពលជីវឧស្ម័ន។
  ៤. ពង្រឹងសមត្ថភាពទាំងបច្ចេកទេស និងទាំងស្ថាប័នសម្រាប់សិកម្មវៃឆ្លាតដែលធន់អាកាសធាតុ (CSA) និងបង្កើតបរិយាកាសគោលនយោបាយមួយដែលអាចធ្វើទៅបានសម្រាប់អាជីវកម្មប្រកបដោយភាតរៈបរិស្ថាន។

# សមាសភាគចម្បងៗនៃគម្រោង

- សមាសភាគទី១៖ កែលម្អហេដ្ឋារចនាសម្ព័ន្ធនៃខ្សែច្រវាក់ផលិតកម្មកសិកម្មឲ្យមានភាពប្រសើរឡើង ហើយធន់នឹងអាកាសធាតុ។

- សមាសភាគទី២៖ ជំរុញការអនុវត្តកសិកម្មវៃឆ្លាត និងកសិធុរៈកិច្ចមានលក្ខណៈស្របទៅនឹងអាកាសធាតុ។

- សមាសភាគទី៣៖ ការរៀបចំឲ្យមានបរិយាកាសល្អសម្រាប់ការវិនិយោគកសិធុរៈកិច្ចប្រកបដោយភាពធនរៈបរិស្ថាន។

# សមាសភាគ១៖ កែលម្អហេដ្ឋារចនាសម្ព័ន្ធនៃខ្សែច្រវ៉ាក់ផលិតកម្ម កសិកម្មឲ្យមានភាពប្រសើរឡើង ហើយធន់នឹងអាកាសធាតុ

- (១) ការស្តារប្រពន្ធ័ធារាសាស្រ្ត និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក (ប្រពន្ធ័ធារាសាស្រ្ត ស្រះទឹក និងប្រព័ន្ធដំណក់ទឹក) ដែលមានលក្ខខ័ណ្ឌធន់ទ្រាំទៅនឹងអាកាសធាតុ។
- (២) ធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវ៉ាក់តម្លៃរបស់សហគម្មន៍កសិកម្ម (លានហាល ដំណើរការផលិត និងឃ្លាំងស្តុក)។
- (៣) ធ្វើឲ្យប្រសើរឡើងនូវការតភ្ជាប់ពីស្រែទៅសហគមន៍ និងទៅទីផ្សារតាមរយៈបណ្តាញផ្លូវលំជនបទដែលធន់ទ្រាំនឹងអាកាសធាតុ។
- (៤) ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់គុណភាពកសិកម្ម និងការធ្វើតេស្តសុវត្ថិភាព និង
- (៥) ការលើកកម្ពស់ថាមពលដែលអាចប្រើបាន (ឡជីវឧស្ម័ន និងការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យក្នុងតំបន់សហគមន៍កសិកម្មគោលដៅ) ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទាំងកញ្ចក់ GHG ។

# សមាសភាគទី២៖ ការជំរុញការអនុវត្តកសិកម្ម និងកសិ-ធុរៈកិច្ចមានលក្ខណៈស្របទៅនឹងអាកាសធាតុ

- (១) បញ្ចេញពូជដែលធនទៅនឹងអាកាសធាតុ
- (២)ការពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តផលិតកម្មដោយភាគរៈបរិស្ថាននិងបច្ចេកវិទ្យា
- (៣) លើកកម្ពស់គ្រឿងយន្តកសិកម្ម និងការការផ្សព្វផ្សាយ។

- គម្រោងនឹងបណ្តុះបណ្តាលកសិករ និងសមាជិកសហគមន៍កសិកម្មស្តីពីកសិកម្មវៃឆ្លាតធននឹងអាកាសធាតុ។ មិនតែប៉ុណ្ណោះគម្រោងនឹងធ្វើបង្ហាញការពង្រាបដីដោយប្រព័ន្ធឡាស៊ែរ ដើម្បីធ្វើអោយប្រសើឡើងនូវប្រសិទ្ធភាពការប្រើប្រាស់ទឹក និងលើកកម្ពស់សមត្ថភាពក្រុមកសិករប្រើប្រាស់ទឹកក្នុងការប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធធារាសាស្រ្ត។ គម្រោងនឹងសាងសង់ និងធ្វើអោយប្រសើរឡើងនូវរោងជាងគ្រឿងយន្តកសិកម្ម និងបំពាក់សម្ភារបណ្តុះបណ្តាលកសិធុរៈកិច្ច ដើម្បីបណ្តុះបណ្តាលសហគមន៍កសិករប្រើប្រាស់ទឹក កសិករជាស្រ្តី និងសមាជិកសហគមន៍កសិកម្មក្នុងការគ្រប់គ្រង និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងយន្តកសិកម្ម។

# សមាសភាគទី៣៖ ការរៀបចំឲ្យមានបរិយាកាសល្អសម្រាប់ការវិនិយោគ កសិធុរកិច្ចប្រកបដោយភាតរៈបរិស្ថាន

- បង្កើតស្តង់ដា និងគោលនយោបាយកសិធុរកិច្ចប្រកបដោយភាតរៈបរិស្ថាន ជម្រុញហិរញ្ញវត្ថុបៃតង និងយន្តការចែករំលែកហានិភ័យ និងគាំទ្រការគ្រប់គ្រងហានិភ័យ អាកាសធាតុ តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា។ គម្រោងនឹងផ្តល់ជូននូវវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្មកសិកម្ម គុណភាព និងស្តង់ដាភាពសាំ ក្នុងនោះរួមមានការអនុវត្តកសិកម្មល្អកម្ពុជា និងស្តង់ដាជីសរីរាង្គ។

- គម្រោងនឹងគាំទ្រសហគមន៍កសិកម្មក្នុងការប្រកបអាជីវកម្មកសិ-ធុរៈកិច្ចប្រកបដោយនិរន្តរភាពដោយផ្សារភ្ជាប់ជា មួយវិស័យឯកជន និងដោយបង្កើតវេទិកាភាពជាដៃគូរដ្ឋឯកជនដោយផ្តោតទៅលើដំណាំ។ គម្រោងនឹងបង្ហាញចំណេះដឹងនៃស្ថាប័នហិរញ្ញវត្ថុ ស្តីពីហិរញ្ញវត្ថុបៃតង និងការធ្វើសមាហរណកម្មវិនិច្ឆ័យជម្រុះហានិភ័យអាកាសធាតុ និងបរិស្ថានទៅក្នុងការអនុវត្តប្រព័ន្ធក្រេឌីត និងនីតិវិធីធ្វើរបាយការណ៍។ គម្រោងនឹងផ្តល់ព័ត៌មានអាកាសធាតុ ទីផ្សារ និងក្សេត្រសាស្ត្រ ដើម្បីបង្កើតបរិយាកាសមួយសម្រាប់ការគ្រប់គ្រងហានិភ័យអាកាសធាតុកាន់តែមានប្រសិទ្ធិភាព ដោយការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។

# ១.សេចក្តីផ្តើម

## តើអ្វីជាការប្រែប្រួលអាកាសធាតុ?

- ការប្រែប្រួលអាកាសធាតុនៅលើសាកលលោកឬ នៅក្នុងតំបន់ក្នុងរយៈពេលយូរមកហើយដោយ៖
  - ការកើនឡើងកំដៅ និងសីតុណ្ហភាពកើនឡើង
  - ការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG: $CO_2$, $CH_4$, $N_2O$, HFCs, PFCs, $SF_6$)
  - គ្រោះរាំងស្ងួតញឹកញាប់
  - ការប្រែប្រួលពេលវេលាធ្លាក់ភ្លៀង និងកំពស់ទឹកភ្លៀង
  - មានខ្យល់ព្យុះខ្យល់កន្ត្រាក់ និងមានទឹកជំនន់
  - ការកើនឡើងកំពស់ទឹកសមុទ្រ ។ល។

# មូលហេតុនៃការប្រែប្រួលអាកាសធាតុ

- ការប្រែប្រួលអាកាសធាតុ កើតឡើងដោយសារកត្តាធម្មជាតិ និងសកម្មភាពរបស់មនុស្ស
  - ការប្រែប្រួលថាមពលព្រះអាទិត្យ ការប្រែប្រួលយឺតៗ នៃគន្លងផែនដីជុំវិញព្រះអាទិត្យ ការប្រែប្រួលចរន្ត ទឹកសមុទ្រ ខ្យល់ ការប្រែប្រួលចរន្តខ្យល់ ដុតឥន្ធនៈហ្វូស៊ីល ការការព្រៃឈើ ការដុតព្រៃឈើ ការសង់ពង្រីកទីក្រុង ទីលានចាក់សម្រាម។ល។







ប្រភព: *Rahmstorf and Schellnhuber,2006*

# ផលប៉ះពាល់នៃឧស្ម័នផ្ទះកញ្ចក់

- ឧស្ម័នផ្ទះកញ្ចក់សំខាន់មាន៦ គឺៈ ឧស្ម័នកាបូនិក ($CO_2$), មេតាន ($CH_4$), ឌីអាសូតអុកស៊ីត ($N_2O$) អ៊ីដ្រូហ្លុយអរ៉ូកាបូន (HFCs) ពែរហ្លុយអរ៉ូកាបូន (PFCs) ស៊ុលភួអិចសាក្លរ ($SF_6$)






ប្រភព ៖ នាយកដ្ឋានប្រែប្រួលអាកាសធាតុ ២០១១

# កសិកម្ម និងកសិកម្មវៃឆ្លាតនឹងអាកាសធាតុ

- កសិកម្មបានចូលរួមដោះស្រាយបញ្ហាប្រឈមពីការប្រែប្រួលអាកាសធាតុ ដើម្បីធានាបានសន្តិសុខស្បៀង និងប្រព័ន្ធស្បៀង តាមរយៈបង្កើនផលិតភាព និងប្រាក់ចំណូល ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងចូលរួមបន្ធូរបន្ថយនឹងការប្រែប្រួលអាកាសធាតុ។
- ការចូលរួមទាំងនេះបានបង្កើនប្រសិទ្ធភាពប្រើប្រាស់ធនធានដូចជាការប្រើប្រាស់ធនធានដី ទឹក និងធាតុចូលកសិកម្មតិច ដើម្បីផលិតស្បៀងឱ្យបានច្រើន និងមាននិរន្តភាព ព្រមទាំងបង្កើនភាពធន់នឹងការប្រែប្រួល និងវិបត្តិនានា។
- គោលគំនិត និងការអនុវត្តកសិកម្មវៃឆ្លាតនឹងអាកាសធាតុ ជាមធ្យោបាយមួយសម្រាប់ដោះស្រាយសន្តិសុខស្បៀងក្នុងបរិបទការប្រែប្រួលអាកាសធាតុ។
- ការអនុវត្តកសិកម្មវៃឆ្លាតនឹងអាកាសធាតុ គឺដើម្បីកែលម្អសន្តិសុខស្បៀង ជួយដល់កសិករ និងសហគមន៍បន្សាំនឹងការប្រែប្រួលអាកាសធាតុ និងចូលរួមបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុសកល ការបង្កើតគោលនយោបាយ វិធីសាស្ត្រគាំទ្រនៃតម្រូវការ។

# អ្វីទៅជាកសិកម្មវៃឆ្លាតនឹងអាកាសធាតុ?
## What is Climate Smart of Agriculture?

កសិកម្មវៃឆ្លាតនឹងអាកាសធាតុ

- ជាអភិក្រម ឬវិធីសាស្ត្រក្នុងការបង្កើតនូវលក្ខខណ្ឌបច្ចេកទេស គោលនយោបាយ និងការវិនិយោគ ដើម្បីទទួលបាននូវនិរន្តរភាពនៃការអភិវឌ្ឍកសិកម្ម សម្រាប់សន្តិសុខស្បៀងក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ (FAO, 2010)

- កសិកម្មវៃឆ្លាតនឹងអាកាសធាតុមិនខុសពីកសិកម្មប្រកបដោយនិរន្តរភាពទេ។ ផ្ទុយទៅវិញវាជាវិធីនៃការរួមបញ្ចូលគ្នានូវវិធីសាស្ត្រប្រកបដោយនិរន្តរភាពផ្សេងៗ ដើម្បីដោះស្រាយបញ្ហាប្រឈមអាកាសធាតុរបស់សហគមន៍កសិកម្មជាក់លាក់មួយ។

# ២. សរសរស្តម្ភនៃកសិកម្មវៃឆ្លាតនឹងអាកាសធាតុ (CSA)

## កសិកម្មវៃឆ្លាតនឹងអាកាសធាតុ (CSA)




បង្កើននិរន្តរភាព ផលិតភាពកសិកម្ម និងប្រាក់ចំណូល




បន្សាំ និងបង្កើតសមត្ថភាពធន់នឹងអាកាសធាតុ




កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលរួមចំណែកឱ្យមានការប្រែប្រួលអាកាសធាតុ

# កសិកម្មវៃឆ្លាតនឹងអាកាសធាតុ (CSA)

## សសរស្តម្ភទី ១

**១) បង្កើនផលិតភាពកសិកម្ម និងប្រាក់ចំណូលប្រកបដោយនិរន្តរភាព**




- ធ្វើឱ្យការគ្រប់គ្រងដីជាតិដីបានល្អប្រសើរឡើង
- បង្កើនផលិតភាពតាមរយៈការប្រើពូជដែលមានទិន្នផលខ្ពស់
- បង្កើនផលិតភាពកសិកម្មតាមរយៈការធ្វើពិពិធកម្មក្នុងផលិតកម្មកសិកម្ម
- ការកាត់បន្ថយថ្លៃដើមក្នុងផលិតកម្មតាមរយៈការកាត់បន្ថយការចំណាយលើធាតុចូលដូចជា គ្រាប់ពូជ ជីគីមី និងថ្នាំកសិកម្ម ជាដើម។

# កសិកម្មវៃឆ្លាតនឹងអាកាសធាតុ ( CSA )

## សសរស្តម្ភទី ២

**២) បន្សាំ និងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ**




- ធ្វើឱ្យប្រសើរឡើងនូវការសន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធនានាសន្សាំនឹងទឹកជំនន់
- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងទឹក ដើម្បីសន្សាំនឹងគ្រោះរាំងស្ងួត
- ធ្វើឱ្យប្រសើរឡើងនូវការការពារ និងព្យាបាលជំងឺដល់សត្វ និងដំណាំ

# កសិកម្មវៃឆ្លាតធន់នឹងអាកាសធាតុ (CSA)

## សរសរស្តម្ភទី ៣

**៣) កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលរួមចំណែកឱ្យមាន ការប្រែប្រួលអាកាសធាតុ**




- កាត់បន្ថយការកាប់បំផ្លាញព្រៃឈើដើម្បីពង្រីកកសិកម្ម
- កាត់បន្ថយការប្រើប្រាស់ធាតុចូលគីមីផ្សេងៗ ដែលមានឥទ្ធិពលដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់
- បង្កើនការចាប់យកឧស្ម័នផ្ទះកញ្ចក់ចូលទៅក្នុងដី និងជីវម៉ាស់
- ងាកមកពឹងផ្អែកលើការប្រើប្រាស់ប្រភពថាមពលមិនមែនឥន្ធនៈ (ថាមពលកកើតឡើងវិញ)

# ៣. បច្ចេកទេសសំខាន់ៗដែលធន់នឹងអាកាសធាតុក្នុងផលិតកម្មកសិកម្ម

ADB GREEN CLIMATE FUND

**១) ការរៀបចំផែនការអាជីវកម្ម**

ក. ការរៀបចំប្រតិទិនដាំដុះដំណាំ
ខ. ការកត់ត្រាក្នុងផលិតកម្ម
គ. ការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ច

**៣) វិធីសាស្រ្តដាំដុះ**

ក. ការរៀបចំដី៖ ការកៀរពង្រាបដីដោយប្រព័ន្ធឡាសែរ ស្វ័យប្រវត្តិ
ខ. ពង្រោះស្រូវគ្រាប់សើម (Drum seeder, Eli seeder) ដោយម៉ាស៊ីន
គ. ពង្រោះស្រូវគ្រាប់ស្ងួត
ឃ. ការស្ទូង (SRI និង ម៉ាស៊ីនស្ទូង)

**៥) ការគ្រប់គ្រងជីជាតិដី**

ក. ការប្រើប្រាស់ជីសរីរាង្គ (កំប៉ុស្តិគោក/ទឹក ធ្យូងអង្កាម ជាដើម)
ខ. ជីស្រស់/ដំណាំគម្របដី
គ. ការធ្វើពិពិធកម្មដំណាំ
ឃ. កសិកម្មអភិរក្ស

**២) គុណភាពគ្រាប់ពូជ**

ក. ការប្រើប្រាស់គ្រាប់ពូជមានគុណភាព(សុទ្ធ)
ខ. ការជ្រើសរើសប្រភេទពូជ

**៤) ការគ្រប់គ្រងទឹក**

ក. បច្ចេកទេសពន្លិច និងបង្ហោក (AWD)
ខ. ប្រព័ន្ធបូមទឹកដោយពន្លឺព្រះអាទិត្យ
គ. ការប្រមូលផលទឹកភ្លៀងរក្សាទុក

**៦) វិធានការចម្រុះគ្រប់គ្រងដំណាំ (IPM)**

ប្រើបច្ចេកទេសIPMទាំង៥ ដើម្បីគ្រប់គ្រងដំណាំ

**៧) ការគ្រប់គ្រងក្រោយប្រមូលផល**

ក. ការកំណត់ពេលវេលាប្រមូលផល
ខ. បច្ចេកទេសទុកដាក់
គ. ការគ្រប់គ្រងចំបើង៖ ចំណីសត្វ ផលិតកម្មផ្សិត ការធ្វើជីកំប៉ុស្ដិ៍ និងធ្យូងអង្កាម

**៨) ប្រព័ន្ធផលិតកម្មទំនើបចម្រុះ**

ក. ប្រព័ន្ធផលិតកម្មស្រូវ និងត្រី
ខ. ផលិតកម្មស្រូវសរីរាង្គ
គ. ផលិតកម្មស្រូវនិរន្តរភាព (SRP)

# ១. ការរៀបចំផែនការអាជីវកម្ម



# តារាងគណនាប្រសិទ្ធិភាពសេដ្ឋកិច្ចសម្រាប់កសិករ

ឈ្មោះពូជ..................................អាយុកាល.....................ថ្ងៃខែឆ្នាំដាំដុះ.............

១. ការជ្រើសរើស

| បរិយាយចំណាយ | ចំនួន/ឯកតា | តម្លៃ (៛) | តម្លៃសរុប(៛) |
|---|---|---|---|
| **ការរៀបចំដី :**<br>- សំរាប់សាប ( ភ្ជួរ រាស់ )<br>- ភ្ជួរដាស់ដី<br>- សំរាប់ស្ទូង ( ភ្ជួរ- រាស់ ) | | | |
| **សំភារះ**<br>- គ្រាប់ពូជ<br>- ជី<br>- ថ្នាំពុល | | | |

| | | | |
|---|---|---|---|
| **កំលាំងពលកម្ម :** ( ជួល)<br>- ជួលសាប<br>- ដកសំណាប<br>- ជួលស្ទូង<br>- ថ្ងៃច្រូតកាត់<br>- បោកបែន | | | |
| **ឧបករណ៏ :**<br>- ម៉ាស៊ីនបូមទឹក<br>- ការដឹកជញ្ជូន<br>- ឧបករណ៏ផ្សេងៗ | | | |
| **សរុបរួម** | | | |

## ២- ប្រាក់ចំណូល

| បរិយាយ | ឯកត្តា | តំលៃរាយ | តំលៃសរុប |
|---|---|---|---|
| - ទិន្នផលស្រូវ<br>- ចំបើង | | | |
| សរុបរួម | | | |

## ៣- ប្រាក់ចំនេញ ៖

ប្រាក់ចំណូល - ប្រាក់ចំណាយ = ……………………………………?

# ការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ច

- ការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ច គឺដើម្បីបានស្វែងយល់អំពីផលចំណេញ/ខាត ដែលនឹងទទួលបាននៅក្នុងផលិតកម្មមួយ ដែលបានរៀបចំ អនុវត្តន៍ លើផ្ទៃដីណាមួយជាក់លាក់
- ស្វែងយល់អំពីតម្លៃថ្លៃដើមផលិតកម្មក្នុង១ឯកតា
- បានស្វែងយល់ពីកត្តាណាមួយដែលបានជះឥទ្ធិពល ដល់ដំណើរការនៅក្នុងផលិតកម្ម
- ងាយស្រួលផលិតករធ្វើសេចក្ដីសម្រេចចិត្តជាថ្មីនៅក្នុងផលិតកម្ម (ជំរុញ បង្កើន កាត់បន្ថយ បោះបង់.....?)។

# ២. គុណភាពគ្រាប់ពូជ









# ការប្រើប្រាស់គ្រាប់ពូជសុទ្ធនិងប្រភេទពូជ

## លក្ខណៈរបស់គ្រាប់ពូជស្រូវ

- គ្រាប់ពូជសុទ្ធ ដោយគ្មានលាយជាមួយគ្រាប់ពូជស្រូវដទៃ និងគ្រាប់ស្មៅ
- គ្រាប់ពេញ ទំហំប៉ុនគ្នា មានពណ៌ភ្លឺថ្លា
- គ្រាប់ពូជគ្មានជំងឺ និងស្នាមបំផ្លាញ
- អត្រាដំណុះខ្ពស់ចាប់ពី ៨០% ឡើងទៅ
- គ្រាប់ពូជដែលមានសំណើមចាប់ពី ១២ ទៅ១៤%។



## ការជ្រើសរើសប្រភេទពូជ

- ជ្រើសរើសប្រភេទពូជដែលត្រូវនឹងរដូវកាលដាំដុះនិងក្សេត្របរិស្ថានតំបន់
- ប្រើប្រាស់ប្រភេទគ្រាប់ពូជសុទ្ធ
- ជ្រើសប្រភេទពូជដែលមានតម្រូវការទីផ្សារ
- ប្រភេទពូជដែលមានប្រភពច្បាស់លាស់
- ប្រភេទដែលមានកិច្ចសន្យាកសិកម្ម
- ប្រភេទពូជដែលទទួលបានអង្គរមានគុណភាពខ្ពស់ និងមានតម្លៃខ្ពស់។

# ៣. វិធីសាស្រ្តដាំដុះ

➢បច្ចុប្បន្ន យើងឃើញមានវិធីសាស្រ្តដាំដុះ ដំណាំស្រូវជាច្រើនប្រភេទដែលកសិករនិយមមានដូចជា៖

១/ ការដាំដោយស្ទូង

ស្ទូងដោយម៉ាស៊ីនទំនើប

ស្ទូងដោយដៃ

២/ ការពង្រោះគ្រាប់

ពង្រោះដោយម៉ាស៊ីនទំនើប

ពង្រោះដោយដៃ

និងការប្រើប្រាស់បរិមាណគ្រាប់ពូជផ្សេងៗគ្នា

# ការកៀរពង្រាបដីឱ្យបានរាបស្មើ

- ការកៀរពង្រាបដីស្រែមានគុណសម្បត្តិដូចជា៖
  - កាត់បន្ថយបរិមាណទឹកស្រោចស្រពរហូត ៣០%
  - ចំណេញពេលវេលាពី ១០-១៥%
  - កាត់បន្ថយស្មៅដុះក្នុងស្រែបានរហូតដល់ ៤០%
  - ធ្វើឱ្យដំណាំស្រូវដុះលូតលាស់ស្មើគ្នាល្អ និងទុំស្រុះគ្នា
  - ផ្តល់ទិន្នផលខ្ពស់ (នៅកម្ពុជា ការកៀរពង្រាបដីស្មើល្អបង្កើនទិន្នផល២៤% ឬ ៥៣០ kg/ha)
  - ទទួលបានគុណភាពស្រូវល្អ





- វីដេអូស្តីពីការកៀពង្រាបដី៖ https://www.youtube.com/watch?v=KNgakpK4GHc

# សកម្មភាពការកៀពទ្រាបដី






- វីដេអូស្តីពីការកៀពង្រាបដី៖ https://www.youtube.com/watch?v=KNgakpK4GHe

# សកម្មភាពវិធីសាស្ត្រដាំដុះរបស់កសិករ





Planting seed at Rice School, at Los Banos in the Philippines



# ការដាំគ្រាប់ស្រូវស្ងួតជាជួរដោយម៉ាស៊ីន





ដាំដោយឧបករណ៍បំពាក់ពីក្រោយត្រាក់ទ័រ ( VENCE TUDO)





ដាំដោយ Thaikit

# ការស្ទូងដោយប្រើម៉ាស៊ីនទំនើប









# ៤.ការគ្រប់គ្រងទឹក

## ប្រព័ន្ធបូមទឹកដោយប្រើពន្លឺព្រះអាទិត្យ




Solar irrigation system





https://www.khmerenergy.com/custom-solar-power

# បច្ចេកទេសពន្លិច និងបង្ហោក (AWD)




បំពង់ទឹកដែលអាចប្រើសម្រាប់កំណត់ពេលវេលាស្រោចស្រពដោយតាមដានការធ្លាក់ចុះជម្រៅទឹកនៅខាងក្នុងបំពង់ទឹក




១. ២ សប្តាហ៍បន្ទាប់ពីស្ទូង ត្រូវទុកឱ្យស្ងួត ហើយចន្លោះរយៈពេលស្រោចស្រពនៃ AWD អាចប្រែប្រួលពី ២-១០ ថ្ងៃ។

២. នៅពេលកម្រិតទឹកថយចុះ ១៥ cm ខាងក្រោមផ្ទៃដី ការស្រោចស្រពត្រូវបានពន្លិចវិញរហូតដល់កម្ពស់ទឹក ៥ cm ។

**សំគាល់៖** ស្រែត្រូវរក្សាទឹកកម្ពស់ ៥ cm នៅមុនពេលដំណាក់កាលចេញផ្ការហូតដល់១សប្តាហ៍ ក្រោយដំណាក់កាលចេញផ្កា

# ការប្រមូលផលទឹកស្តុកនិងការប្រើប្រាស់



https://www.villagesquare.in/rainwater-l





អាងស្តុកទឹក



ការជីកស្រះទឹកក្នុងចម្ការ





# ការប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធិភាព

- **ការលើកភ្លឺស្រែឱ្យបានស្អាតល្អ៖**
  - ថែរក្សាទឹកក្នុងស្រែ
  - កាត់បន្ថយបាននូវស្មៅចង្រៃដុះ
  - កាត់បន្ថយការបាត់បង់ ហូរចេញនូវជីជាតិដែលបានផ្គត់ផ្គង់
  - ធ្វើឱ្យដំណាំស្រូវដុះលូតលាស់ស្មើគ្នាល្អ និងទុំស្មើគ្នា

**សម្អាតភ្លឺស្រែឱ្យបានស្អាតជានិច្ច៖**

  - កាត់បន្ថយកត្តាជំរកសត្វល្អិត ជំងឺ
  - ទទួលបានគុណភាពស្រូវល្អ

# ៥.គ្រប់គ្រងសារធាតុចិញ្ចឹម

## ការប្រើប្រាស់ជីឱ្យសមស្រប

- ការប្រើប្រាស់ជីឱ្យបានត្រឹមត្រូវទៅតាមតម្រូវការរបស់ដំណាំ ដោយផ្អែកលើ៖
  - បទដ្ឋាននៃការប្រើប្រាស់ជីតាមតំបន់ឬអនុសាសន៍របស់បច្ចេកទេស
  - ប្រើប្រាស់ Soil Test Kit
  - Leaf Color Chart








*40% input cost has been decreased after using the soil test kit - BRIA Indonesia, GIZ project*



# ការប្រើប្រាស់ជីធម្មជាតិកែប្រែគុណភាពដី

- ប្រើប្រាស់ជីកំប៉ុស្ដិ៍ ធ្យូងអង្កាម កាកសំណល់ឡជីវឧស្ម័ន និងជីស្រស់ ដើម្បីបង្កើនជីជាតិដី
- ការប្រើប្រាស់ជីសរីរាង្គរួមផ្សំនឹងជីគីមី
- បច្ចេកទេសគ្រងគ្រងសំណឹកដី (ឧ. ដាំដំណាំគម្របដី ការដាំដំណាំបង្វិល ជាដើម)







# ការធ្វើពិពិធកម្មដំណាំលើដីស្រែ

- បង្កើនប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារ
- អាចទប់ទល់នឹងការប្រែប្រួលតម្លៃផលិតផល
- កាត់បន្ថយនូវផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- បង្កើនតុល្យភាពអាហារសម្រាប់គ្រួសារ
- ជាប្រភពបន្ថែមសម្រាប់ធ្វើចំណីសត្វ
- ជួយអភិរក្សធនធានធម្មជាតិ
- កាត់បន្ថយការបំពុលបរិស្ថាន
- ការបន្ថយការពឹងផ្អែកលើធាតុចូលក្រៅកសិដ្ឋាន (ជី និងថ្នាំពុលគីមី)
- ផ្អែកលើការដាំដំណាំបង្វិលអាចជួយកាត់បន្ថយសត្វល្អិត ជំងឺ និងស្មៅចង្រៃ
- បង្កើនសន្តិសុខស្បៀងក្នុងសហគមន៍។





https://qcat.wocat.net/en/wocat/technologies/view/technologies_1890/



# ៦. វិធានការចម្រុះគ្រប់គ្រងដំណាំ

➢វិធានការចម្រុះគ្រប់គ្រងដំណាំគឺជាប្រពន្ធ័គ្រប់គ្រងដំណាំដែលរួមបញ្ចូលនូវគ្រប់វិធីសាស្រ្តទាំងអស់ដើម្បីថែរក្សានិងការពារដំណាំឱ្យដុះលូតលាស់ល្អ ទទួលបានទិន្នផលខ្ពស់ធានាបាននូវនិរន្តរភាពផលិតកម្ម ប្រសិទ្ធិភាពសេដ្ឋកិច្ច និងការពារសុខមាលភាពរបស់កសិករនិងបរិស្ថាន។

គោលការណ៍គ្រិៈសំខាន់ៗរបស់កម្មវិធី (IPM) ចំនួន៤ មានដូចតទៅ៖

១/ ដាំដំណាំឱ្យដុះលូតលាស់ល្អ៖ ត្រូវជ្រើសរើសពូជឱ្យបានល្អ ទិន្នផលខ្ពស់ ធន់នឹងសត្វល្អិត ជំងឺ និងសមស្របលក្ខខណ្ឌក្នុងតំបន់។

២/ ថែរក្សាសត្វមានប្រយោជន៍៖ ត្រូវស្វែងយល់ឱ្យបានច្បាស់អំពីប្រភេទសត្វ និងបរិមាណសត្វស៊ីដំណាំ វត្តមានសត្វមានប្រយោជន៍ក្នុងស្រែ/ចំការលក្ខណៈនៃការរស់នៅនិងការស៊ីចំណីរបស់សត្វនីមួយៗ។

៣/ចុះពិនិត្យស្រែជាប្រចាំ៖ គឺជាការងារចាំបាច់បំផុត ដែលធ្វើឱ្យកសិករបានពិនិត្យ និងវាយតម្លៃអំពីស្ថានភាពស្រែ លក្ខណលូតលាស់របស់ដំណាំ ស្ថានភាពទឹក ដី ស្មៅចង្រៃ វត្ថុមានសត្វមានប្រយោជន៍ វត្ថុមានសត្វស៊ីដំណាំនិងស្ថានភាពនៃការបំផ្លាញរបស់វានៅតាមតំណាក់កាលនិងវគ្គលូតលាស់នីមួយៗរបស់ដំណាំ។

៤/ កសិករក្លាយជាអ្នកជំនាញក្នុងផលិតកម្មដំណាំ៖ បង្កើនសមត្ថភាពកសិករឱ្យចេះពិនិត្យស្ថានភាពស្រែ ចេះវិភាគ និងធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងប្រកបដោយភាពវៃឆ្លាត តាមរយៈការធ្វើពិសោធន៍ ការផ្លាស់ប្តូរបច្ចេកទេសជាមួយអ្នកបច្ចេកទេសនិងកសិករក្នុងតំបន់ ដើម្បីបង្កើនភាពជឿជាក់និងពឹងផ្អែកលើខ្លួនឯង។

# វិធានការការពារនិងកម្ចាត់ ( IPM )

១/ វិធានការដាំដុះ/កសិក្រសាស្ត្រ ៖

២/ វិធានការជីវសាស្ត្រ៖

៣/ វិធានការមេកានិច៖

៤/ វិធានការគីមីសាស្ត្រ៖

# ៧.ការគ្រប់គ្រងក្រោយប្រមូលផល

## ការកំណត់ពេលប្រមូលផល

**1**

ពណ៌គ្រាប់ និង ចំបើង



៨០-៨៥% ទុំពណ៌លឿង

**2**

សំណើម



សំណើមចន្លោះ ២១-២៤%

**3**

| ចំនួនថ្ងៃក្រោយចេញកួរ | |
|---|---|
| ២៨- ៣៥ ថ្ងៃ (រដូវប្រាំង) | ៣២- ៣៨ ថ្ងៃ (រដូវវស្សា) |

**4**

| Number of days after sowing | | |
|---|---|---|
| **130 – 136 days** for **late-maturing** varieties | **113 – 125 days** for **medium-maturing** varieties | **110 days** for **early-maturing** varieties |

**5**

**Hardness** of the lower parts of the panicle



**"hard-dough" stage (firm but not brittle)**

# ការស្តុកទុក

- សំណើម១៣-១៤% សម្រាប់ស្រូវចំណី និង ១២% សម្រាប់គ្រាប់
- ទុកនៅកន្លែងសុវត្ថិភាព គ្មានការបំផ្លាញពីកត្តាចង្រៃ
- ប្រព័ន្ធស្តុកទុកបិទជិត (Hermetic storage systems):
  - Cocoon
  - IRRI supper bag
  - ធុងបិទជិត















# ការគ្រប់គ្រងជញ្ជ្រាំង និងចំបើង

- ជៀសវាងដុតចំបើង
- ប្រមូលធ្វើចំណីសត្វ
- សម្រាប់ដាំផ្សិត
- ធ្វើជីកំប៉ុស្តិ៍ កែលម្អដី



Figure 43. Delignification of rice straw for cattle feed





Figure 44. Complete feed block for animal feed.



Figure 46.Mushroom production.



Figure 47. Composting as source of bio-fertilizer.



Figure 38. Using rice straw as livestock feed

## ១- ការដាំឆ្លាស់ ( Intercropping )



- ការដាំដំណាំឆ្លាស់គឺជាការដាំដំណាំចាប់ពី២ ឬច្រើនប្រភេទនៅក្បែរ ឬបន្ទាប់គ្នាក្នុងពេលតែមួយ

- គោលបំណងសំខាន់គឺដាំដំណាំច្រើនមុខក្នុងផ្ទៃដីតែមួយ បង្កើនទិន្នផល ប្រើប្រាស់ដីជាតិត្រឹមត្រូវ និងកាត់បន្ថយសត្វល្អិត។



# ២- ការដាំបង្វិល (Crop rotation)

- ការដាំដំណាំបង្វិលគឺជាការដាំ ជាបន្តបន្ទាប់នៃប្រភេទដំណាំ ខុសៗគ្នានៅក្នុងផ្ទៃដីតែមួយទៅ តាមរដូវក្រោយៗទៀត

- វាជួយកាត់បន្ថយការហូរច្រោះ ដី បង្កើនជីជាតិដី និងទិន្នផល ដំណាំ



# ៣- ការដាំលាយ ( Mixed cropping )



- ការដាំដំណាំលាយគឺ ជាប្រព័ន្ធដែលដាំដំណាំ២ ឬ ៣ប្រភេទផ្សេងគ្នានៅលើដីតែមួយ ដែលដំណាំមួយជាដំណាំសំខាន់ និងដទៃទៀតជាដំណាំបន្ទាប់បន្សំ។

- គោលបំណងគឺ កាត់បន្ថយការបាត់បង់ ឬបរាជ័យ ផ្តល់ស្បៀង និងចំណីសត្វ ព្រមទាំងធានានូវតុល្យភាពប្រព័ន្ធអេកូឡូស៊ី



# ៤- ការដាំដំណាំគម្របដីធ្វើជីស្រស់ (Green manure)

- ការដាំដំណាំធ្វើជាជីស្រស់ វានឹងផ្តល់ប្រយោជន៍យ៉ាងធំធេងដល់ការកែលម្អដី សម្រាប់ការដាំដំណាំបន្តបន្ទាប់ទៀត



- ជាទូទៅវាជួយកែលម្អដី បង្កើនសារធាតុសរីរាង្គ និងជីជាតិដី ឬអាចគ្រប់គ្រងស្មៅចង្រៃ



# ៥- ការផលិតជីធម្មជាតិ (កំប៉ុស្ត៍ ជីទឹកធម្មជាតិ)








# ៦.ប្រព័ន្ធស្រោចស្រពវៃឆ្លាត
# ( Drip & Sprinkler irrigation )

- **ផ្តល់អត្ថប្រយោជន៍៖**
  - គ្រប់គ្រងសំណើមដីបានល្អ
  - បង្កើនទិន្នផល
  - សន្សំសំចៃទឹក ជី ថាមពល និងពលកម្ម
  - ការស្រូបយកជីមានប្រសិទ្ធភាព
  - អាចស្រោចស្រពគ្រប់កន្លែង
  - កាត់បន្ថយការដុះស្មៅ សត្វល្អិត និងជម្ងឺ
  - ការអនុវត្តដាំដុះងាយស្រួល





- **គុណវិបត្ត**
  - តម្លៃខ្ពស់
  - ការងារច្រើនពេលចាប់ផ្តើមដំបូង និងចុងក្រោយ
  - ត្រូវការថែទាំជាប្រចាំ
  - ការរក្សាទឹកក្នុងដីតិច

# ៧- ការប្រើផ្ទះសំណាញ់ឬកញ្ចក់

- ផ្ទះសំណាញ់ ឬកញ្ចក់គឺជាគម្រប ការពារដំណាំពីកត្តាខាងក្រៅដូចជា ត្រជាក់ ឬក្តៅខ្លាំង សត្វល្អិតចង្រៃ
- អាចបង្កលក្ខខណ្ឌងាយស្រួលក្នុងការ ដាំដំណាំពេញមួយឆ្នាំដូចជាបន្លែ ឈើ ហូប ផ្លែ ផ្កាជាដើម





## ផលប្រយោជន៍:

- កាត់បន្ថយរដូវដាំដុះ
- ការពារធាតុអាកាសខាងក្រៅ
- ដាំដំណាំច្រើនប្រភេទ
- ការពារឬសត្វល្អិត និងជម្ងឺ

# ៨. ប្រព័ន្ធដាំដំណាំមិនប្រើដី
# ( Soilless farming system )

## 1- អ៊ីដ្រូប៉ូនិក ឬការដាំបន្លែលើទឹក ( Hydroponic )

- អ៊ីដ្រូប៉ូនិក ឬការដាំបន្លែលើទឹក គឺការដាំលើសូលុយស្យុងទឹកដែលមានលាយសារធាតុគីមីចិញ្ចឹមរួចជាស្រេចសម្រាប់ផ្គត់ផ្គង់រុក្ខជាតិ ( ទឹក អុកស៊ីសែន និងសារធាតុចិញ្ចឹមគីមី )



## 2- អខ្វាប៉ូនិក (Aquaponic)

- អខ្វាប៉ូនិក (Aquaponic) គឺការបញ្ចូលគ្នារវាងប្រព័ន្ធនៃការដាំបន្លែលើទឹក (Hydroponic) និង ការចិញ្ចឹមត្រី (Aquaculture)
- បច្ចេកទេសពីរនេះគឺបំពេញឲ្យគ្នាទៅវិញទៅមក (ត្រី និងបន្លែ)។





# 3- Aeroponic

Aeroponic គឺខុសពីអ៊ីដ្រូប៉ូនិកដែលមិនដាំដុះលើទឹកទេ។ គេប្រើសូលុយស្យុងសារធាតុចិញ្ចឹមបាញ់ទៅលើប្រព័ន្ធឫសរុក្ខជាតិជាប្រចាំ។

➢ **ផលប្រយោជន៍៖**

- អនុវត្តនៅលើដីមានសារធាតុពុលក្រខ្វក់ ថ្មច្រើន គ្មានដីជាតិ
- ដីតូចចង្អៀត ដូចជានៅទីក្រុង និងជាយក្រុង។
- ប្រព័ន្ធនេះត្រូវការទឹកតិចជាងការដាំនៅលើដី
- ប្រព័ន្ធនេះជាជម្រើសដ៏ល្អសម្រាប់កន្លែងមានប្រភពទឹកតិចតួច
- ផ្តល់ទិន្នផលខ្ពស់ជាងការដាំតាមទំលាប់ ពី ២០ ទៅ៣០%។





ADB

GREEN
CLIMATE
FUND

# សូមអរគុណ!

